ក្រសួងពាក់ព័ន្ធ អគ្គលេខាធិការ-អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

ស ខេង

★★★

## ២-សេចក្តីសម្រេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ១៩៩៩

### សេចក្តីសម្រេចលេខ ៦៣ សសរ

### ស្តីពី

### ការបង្កើតគណៈកម្មការអន្តរក្រសួង

* * *

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញកិច្ចសន្យា ស្តីពីការស្តារផ្លូវ ស្ពាន ថ្នល់ ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ រវាងបញ្ជាការដ្ឋានវិស្វកម្មអគ្គសេនាធិការ និងក្រុមហ៊ុន ហ្សូរីកូ

-តាមសំណើរបស់អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ

### សម្រេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះត្រួតពិនិត្យវាយតម្លៃការស្តារផ្លូវអ្នកខ្មែរ ចាប់ពីខេត្ត កោះកុង ឆ្ពោះទៅត្រពាំង ស្រុកវាលវែង ខេត្ត ពោធិ៍សាត់ ដែលមានសមាសភាពដូចខាងក្រោមនេះ :

១-តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាប្រធាន

២-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិក

៣-តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន ជាសមាជិក

៤-តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ជាសមាជិក

៥-តំណាង អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ជាសមាជិក

៦-ត័ណហ៊ុង សាលាខេត្តកោះកុង (អាជ្ញាធរដែនដី) ជាសមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ចុះដល់ទីកន្លែង ដើម្បីពិនិត្យ និងវាយតំលៃគុណភាពបច្ចេកទេសផ្លូវ ស្ពាន និង លូ ដែលបានធ្វើរួចហើយ និងផ្លូវដែលបានឈូសឆាយហើយ ព្រមទាំងវាយតំលៃឈើដែលកាន កាប់រួចហើយ ដើម្បីធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រាផ្លូវការរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីសំរួលការងារ ។

-មធ្យោបាយធ្វើដំណើរ និងចរិការចុះត្រួតពិនិត្យ ជាបន្ទុករបស់តាមក្រសួងនីមួយៗ ។

-ប្រធានគណៈកម្មការត្រូវអញ្ជើញគ្រប់សមាជិកមកប្រជុំ ដើម្បីពិភាក្សាកំណត់ពេលវេលា និងចុះធ្វើការងារនេះ ។

មាត្រា ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអភិបាលខេត្តកោះកុង ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រីស្តីទី

ហត្ថលេខា និងត្រា

ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៦៤ សសរ

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យវាយតំលៃលើផលប៉ះពាល់ដល់សំណង់ ផ្ទះសំបែង ដីធ្លីប្រជារាស្ត្រនៅតាមកំណាត់ផ្លូវ ជាតិលេខ៣ និង លេខ៦

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី